01043358

E307/9

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 12 / 2014
ម៉ោង (Time/Heure): 10:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២/០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចស្តីអំពីការដាក់ឯកសារដែលបានស្នើឡើងដោយភាគីនានាចូលទៅក្នុងសំណុំរឿង

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីការិយាល័យសហព្រះរាជអាជ្ញា ស្នើសុំដាក់ឯកសារចំនួន ៤៩៩ ឯកសារ ចូលទៅក្នុងសំណុំរឿង និងដាក់លេខឯកសារទាំងនោះ (ឯកសារ E307/8)។ អនុលោមតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E305 សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារដែលបានស្នើឡើង អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង (ឯកសារ E305/13 និង ឯកសារ E305/13/1)។ ឧបសម្ព័ន្ធ គ២ ដែលភ្ជាប់ជាមួយឯកសារ E305/13 មានឯកសារចំនួន ៤៧៣ ឯកសារ។ ឧបសម្ព័ន្ធ ឃ៣ ដែលភ្ជាប់ជាមួយឯកសារ E305/13/1 មានឯកសារបន្ថែមចំនួន ២៦ ឯកសារ ដែលមិនមាននៅក្នុងសំណុំរឿង ០០២ ផងដែរ។ នៅពេលបច្ចុប្បន្ននេះ ភាគីទាំងអស់អាចរកមើលឯកសារទាំងនេះបាន នៅក្នុងឃ្លាំងផ្ទុកឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញាតាមរយៈប្រព័ន្ធគ្រប់គ្រងឯកសារ (Zylab)។ សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង (១) បញ្ចូនឯកសារទាំងអស់ដែលមានក្នុងឧបសម្ព័ន្ធ គ២ និង ឃ៣ ទៅក្នុងសំណុំរឿង (២) ដាក់លេខឯកសារទាំងនេះនៅក្នុងសំណុំរឿង និង (៣) ធ្វើឲ្យឯកសារទាំងនេះអាចរកបាននៅលើ Zylab។

២. អង្គជំនុំជម្រះសាលាដំបូងក៏កត់សម្គាល់ផងដែរថា មេធាវីការពារក្តី ខៀវ សំផន មេធាវីការពារក្តី នួន ជា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានដាក់បញ្ជីឯកសារដែលបានស្នើឡើងរៀងៗខ្លួន អនុលោមតាមដីកាបង្គាប់ ឯកសារ E305 (ឯកសារ E305/12, ឯកសារ E307/5 និងឯកសារ E305/14) ផងដែរ។ បច្ចុប្បន្ននេះ ឯកសារដែលបានស្នើឡើងទាំងនេះ មិនមាននៅក្នុងសំណុំរឿងនោះទេ។

៣. ដោយយល់ឃើញថា មិនមានភាគីណាមួយជំទាស់ទៅនឹងការដាក់ឯកសារទាំងនេះចូលទៅក្នុងសំណុំរឿង ហើយការដាក់ឯកសារទាំងនេះ គឺជាផលប្រយោជន៍យុត្តិធម៌ ដោយសារតែការដាក់ឯកសារនេះ នឹងជួយសម្រួលដល់ការរកមើលឯកសារទាំងនេះ និងការពិភាក្សានៅពេលក្រោយអំពីភាពអាចទទួលយកបាននៃឯក-សារទាំងនេះនោះ អង្គជំនុំជម្រះសាលាដំបូងនឹងដាក់ឯកសារទាំងនេះចូលទៅក្នុងសំណុំរឿង។ ភាគីទាំងអស់អាចរកមើលឯកសារទាំងនេះបាននៅលើ Zylab តាមរយៈលេខយោងឯកសារ ដែលមាននៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយនឹងអនុស្សរណៈនេះ។

៤. អនុស្សរណៈនេះគឺជាការឆ្លើយតបជាផ្លូវការទៅនឹងឯកសារ E307/8។ អង្គជំនុំជម្រះសាលាដំបូងនឹងចេញដីកាកំណត់កាលបរិច្ឆេទក្នុងពេលឆាប់ៗនេះ សម្រាប់ការជំទាស់ និងការពិភាក្សាអំពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងបញ្ជីឯកសារដែលភាគីបានស្នើឡើង។